**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងការពារជាតិ**

# សេចក្តីប្រកាសព័ត៌មាន

ក្រសួងការពារជាតិមានកិត្តិយសសូមជម្រាបជូនដល់សាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិ អំពីការវិវត្តថ្មីៗនៃស្ថានការណ៍នៅតំបន់ព្រំដែនកម្ពុជា-ថៃដូចខាងក្រោម៖

កម្ពុជាមានបំណងរក្សាសុខសន្តិភាព និងរក្សាជំហរដោះស្រាយបញ្ហាព្រំដែនជាមួយភាគីថៃតាមរយៈតុលាការអន្តរជាតិ (ICJ) នៅប្រាសាទតាមាន់ធំ ប្រាសាទតាមាន់តូច ប្រាសាទតាក្របី និងតំបន់មុំបី ដោយសន្តិវិធី និងប្រកបដោយការទទួលខុសត្រូវខ្ពស់។ ក្រៅអំពីនេះ កម្ពុជាបានរៀបចំឱ្យមានកិច្ចប្រជុំគណៈកម្មការចម្រុះព្រំដែន (JBC) ដែលបានប្រព្រឹត្តិទៅនៅថ្ងៃទី១៤-១៥ ខែមិថុនា ឆ្នាំ២០២៥ ហើយបានឯកភាពគ្នាលើកិច្ចការដែលភាគីកម្ពុជា-ថៃត្រូវបំពេញបន្តទៀត។

ជាការសោកស្តាយ ភាគីថៃមិនបានគោរពនូវកិច្ចព្រមព្រៀង ហើយថែមទាំងបានបង្កើនការធ្វើសកម្មភាពរំលោភបំពានលើអធិបតេយ្យ និងបូរណភាពទឹកដីកម្ពុជា ផ្ទុយពីអនុស្សរណៈយោគយល់គ្នាឆ្នាំ២០០០ (MOU2000)។ ភាគីថៃបានបង្កើនសកម្មភាពបង្ហោះដ្រូន ការដឹកលេណដ្ឋាន ការបង្កើន និងចល័តអាវុធគាំទ្រ និងសព្វាវុធគ្រប់ប្រភេទ ការសាងសង់ហេដ្ឋារចនាសម្ព័ន្ធ និងបង្កើនចំនួនទាហាននៅតាមព្រំដែនក្នុងភូមិសាស្ត្រខេត្តព្រះវិហារ និងខេត្តឧត្តរមានជ័យ ដែលជាការគំរាមកំហែងធ្ងន់ធ្ងរដល់សន្តិភាព និងសន្តិសុខនៃប្រទេសទាំងពីរ។

កងទ័ពកម្ពុជាគាំទ្រនូវជំហររបស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងការដោះស្រាយជម្លោះតាមច្បាប់អន្តរជាតិ និងដោយសន្តិវិធី និងរក្សាជំហរយ៉ាងមុតមាំទាំងកងទ័ព ទាំងប្រជាជននៅទូទាំងប្រទេស គោរពអធិបតេយ្យរបស់ប្រទេសជិតខាង និងប្តេជ្ញាប្រែក្លាយតំបន់ព្រំដែនទៅជាតំបន់សន្តិភាព ប៉ុន្តែមិនអនុញ្ញាតជាដាច់ខាតដល់ការប៉ុនប៉ងរំលោភឈ្លានពានពីប្រទេសណាមួយឡើយ ហើយប្តេជ្ញាការពារបូរណភាពទឹកដីទោះជាក្នុងតម្លៃណាក៏ដោយ។

អាស្រ័យដូចបានជម្រាបជូនខាងលើនេះ សូមសាធារណជន អ្នកសារព័ត៌មានជាតិ និងអន្តរជាតិជ្រាបជាព័ត៌មាន។

ថ្ងៃអង្គារ ៧រោច ខែជេស្ឋ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ, ថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០២៥

វិថីហ្សកឌឺមីត្រូវ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ទូរស័ព្ទ-ទូរសារ៖ ០២៣ ៨៨៣ ២៧៤ អ៊ីមែល៖ generalsec@mod.gov.kh

ព្រះរាជាណាចក្រកម្ពុជា
KINGDOM OF CAMBODIA
ជាតិ សាសនា ព្រះមហាក្សត្រ
NATION RELIGION KING

ក្រសួងការពារជាតិ
MINISTRY OF NATIONAL DEFENSE

**PRESS RELEASE**

The Ministry of National Defense has the honor to inform the public, national and international journalists about the latest developments of the situation at the Cambodian-Thai border area as follows:

Cambodia intends to maintain peace and its position to resolve the border issue with the Thai side through the International Court of Justice (ICJ) for Ta Moan Thom Temple, Ta Moan Toch Temple, Ta Krabey Temple and Mom Bei area peacefully and with utmost responsibility. In addition, Cambodia organized a Cambodia-Thailand Joint Commission on Demarcation for Land Boundary (JBC) meeting, held on June 14-15, 2025 and agreed on the tasks that the Cambodian-Thai sides need to complete next.

Unfortunately, the Thai side has not abided by the agreement and has even increased its activities to violate Cambodia's sovereignty and territorial integrity, contrary to the Memorandum of Understanding of 2000 (MOU2000). The Thai side has been increasing the launching of drones, digging trenches, increasing and mobilizing all kinds of weapons and artilleries, building infrastructure, and multiplying the number of soldiers along the border in the provinces of Preah Vihear and Oddar Meanchey, which pose a serious threat to the peace and security of both countries.

The Cambodian military supports the position of the Royal Government of Cambodia in resolving disputes in accordance with international law and through peaceful means, maintains a firm stance, both among the armed forces and the people throughout the country, respects the sovereignty of neighboring countries and is determined to transform the border area into a peaceful area, but does not allow any attempt of aggression from any country, and commits to protect territorial integrity at all costs.

Based on the above information, please the public, national and international journalists be informed.

Phnom Penh, June 17, 2025